ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

12/3

សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងរដ្ឋប្បវេណី
លេខ ៣៥៣ ចុះថ្ងៃទី០៧ ខែ មិនា ឆ្នាំ២០១១
សាលក្រមលេខ ០៧ (គ)
ចុះថ្ងៃទី០៩ខែកុម្ភៈឆ្នាំ២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ដប់ប្រាំសាមសិបនាទី រសៀល ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] **គឹមថា** ភេទស្រី អាយុ ៦៥ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅផ្ទះលេខ ២៩E1 ផ្លូវលេខ៥៥៨ ក្រុម៣៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឯក (រ) ម្ដាយឈ្មោះ [redacted] ធំ (រ) ប្ដីឈ្មោះ [redacted] ប៊ុនយ៉ន។

-ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

១.និងចុងចម្លើយឈ្មោះ [redacted] សាវ៉ែន ភេទស្រី អាយុ ៨៩ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ២៩E0 ផ្លូវលេខ៥៥៨ ក្រុម ៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចាន់ (ស) ម្ដាយឈ្មោះ [redacted] សុខ (ស) ប្ដីឈ្មោះ [redacted] សារិន មានកូន ៣ នាក់។

២.ចុងចម្លើយឈ្មោះ [redacted] សុភាលី ភេទស្រី អាយុ៨៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ ២៩E0 ផ្លូវលេខ៥៥៨ ក្រុម ៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជីម (ស) ម្ដាយឈ្មោះ [redacted] ណារ (ស) ប្ដីឈ្មោះ [redacted] វណ្ណា មានកូន ២ នាក់។

៣.ចុងចម្លើយឈ្មោះ [redacted] ចាន់ណារី ភេទស្រី អាយុ ៨៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ ២៩E0 ផ្លូវលេខ៥៥៨ ក្រុម ៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ទុំ (ស) ម្ដាយឈ្មោះ [redacted] សុខន (ស) ប្ដីឈ្មោះ [redacted] ស៊ីឌី មានកូន ២ នាក់។

**កម្មវត្ថុបណ្ដឹង:**

-ប្ដឹងសុំឱ្យតុលាការចេញសាលក្រម ឱ្យចុងចម្លើយរុះរើរបងស័ង្កសីដែលហ៊ុំព័ទ្ធ លើដីមានទំនាស់ទំហំ៥,៨០ម៉ែត្រ គុណ ៦,៨០ម៉ែត្រ ស្ថិតនៅដីឡូត៍លេខ២៩ ក្រុម៣៧ ផ្លូវលេខ៥៥៨សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានឃើញកំណត់ហេតុត្រៀមសម្រាប់ទាញហេតុផលចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១

-បានឃើញដីកាសម្រេចបញ្ចប់នីតិវិធីត្រៀមនិងដាក់រឿងទាញហេតុផលដោយផ្ទាល់មាត់លេខ ៦៦ តរ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២។



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### ១.ការទាមទាររបស់ដើមចោទ:

-ដើមចោទឈ្មោះ[redacted]គីមថា ប្តឹងសុំឱ្យតុលាការចេញសាលក្រមឱ្យចុងចម្លើយ រុះរើរបងស័ង្កសីចេញដែលហ៊ុំព័ទ្ធលើដីកំពុងមានទំនាស់ ឱ្យដីនៅសភាពដើមដដែល រង់ចាំកម្មាស់កម្មសិទ្ធិពិតប្រាកដសិន។

### ២.ការអះអាងរបស់ភាគី:

-ដើមចោទឈ្មោះ[redacted]គីមថា ដោយមានលោក[redacted]ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនប្តឹងសុំឱ្យតុលាការចេញសាលក្រមឱ្យចុងចម្លើយ រុះរើរបងស័ង្កសីចេញ ដែលហ៊ុំព័ទ្ធលើដីកំពុងមានទំនាស់ទំហំ៥,៨០ ម៉ែត្រ គុណ ៦,៨០ ម៉ែត្រ ស្ថិតនៅដីឡូតិ៍លេខ២៩ ក្រុម ៣៧ ផ្លូវលេខ ៥៥៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឱ្យនៅសភាពដើមវិញ ដើម្បីរកម្ចាស់កម្មសិទ្ធិពិតប្រាដកសិន ដោយហេតុថា ដីមានទំនាស់នេះភូនក្តីខ្លួនបានគ្រប់គ្រងតាំងពីឆ្នាំ១៩៨៨មក តែមានពុំប័ណ្ណសំគាល់សិទ្ធិកាន់កាប់អ្វីទេ ដោយឃើញដីនេះទំនេរភូនក្តីខ្លួនក៏បានធ្វើបន្ទប់សំរាប់ដាក់ម៉ូតូ លុះមកដល់ថ្ងៃទី០៨ ខែកុម្ភះ ឆ្នាំ២០១០ ចុងចម្លើយបានដាក់ពាក្យបណ្តឹងមកតុលាការសុំដីកា សម្រេចរក្សាការពារតុលាការក៏ចេញដីកាសម្រេចការពារដល់ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១០ លោកព្រះរាជអាជ្ញាក៏បានដឹកនាំកំលាំងចុះអនុវត្តដីកានោះ ហើយរុះរើបន្ទប់របស់ខ្លួនអស់ ក្រោយមកចុងចម្លើយឈ្មោះ[redacted] សាវីន [redacted] សុភាលី និងឈ្មោះ[redacted]ចាន់ណារី បាននាំគ្នាយកស័ង្កសីទៅហ៊ុំព័ទ្ធលើដីនេះអស់ សំណូមពរសុំឱ្យចុងចម្លើយរុះរើស័ង្កសីចេញពីដីកំពុងមានទំនាស់នេះឱ្យនៅសភាពដើមដដែល។

-ចុងចម្លើយឈ្មោះ[redacted] ចាន់ណារី បានធ្វើសេចក្តីថ្លែងការណ៍ថា ដីទំនាស់នេះមានទំហំតែ ៨,៨០ម៉ែត្រ គុណ ៦,៨០ម៉ែត្រ ជាដីប្រើរួមទាំងអស់គ្នា ក្រោយមកស្រាប់តែឈ្មោះ[redacted] គីមថា បានមកធ្វើបន្ទប់លើដីរួមនេះ ហើយពួកខ្លួនបានដាក់ពាក្យបណ្តឹងមកតុលាការសុំដីការក្សាការពារ តុលាការបានអនុវត្តរុះរើបន្ទប់នេះ ហើយដើមចោទចេះតែបង្ករឿង ពួកខ្លួនបានហ៊ុំព័ទ្ធស័ង្កសីលើដីជាបណ្តោះអាសន្នសិន ជៀសវាងមានអំពើហិង្សាកើតមានឡើង ពីព្រោះដីនេះមិនទាន់មានម្ចាស់កម្មសិទ្ធិនៅឡើយ ខ្លួនសំណូមពរសុំទុកដីទំនាស់នេះប្រើជាសម្បត្តិរួមទាំងអស់គ្នា។

### ៣.ចំណុចវិវាទ

-ដើមចោទចោទ · សុំឱ្យចុងចម្លើយរុះរើរបងស័ង្កសីដែលហ៊ុំព័ទ្ធលើដីចេញដោយទុកឱ្យនៅសភាពដើមដដែល រីឯចុងចម្លើយមិនព្រមរុះរើចេញទេដោយសុំទុកការហ៊ុំព័ទ្ធស័ង្កសីជាបណ្តោះអាសន្នសិនជៀសវាងការមានទំនាស់ ព្រោះដីនេះមិនទាន់មានម្ចាស់កម្មសិទ្ធិនៅឡើយ។

## សំអាងហេតុ

-ពាក្យសុំរបស់ដើមចោទឈ្មោះ[redacted]គីមថា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ប្តឹងសុំឱ្យចុងចម្លើយឈ្មោះ[redacted] សាវីន ,[redacted] ស៊ីនី ប្រពន្ធឈ្មោះ[redacted] ចាន់ ណារី និងឈ្មោះ[redacted]វណ្ណាប្រពន្ធឈ្មោះ[redacted] សុភាលី រុះរើរបងស័ង្កសីដែលហ៊ុំព័ទ្ធលើដីទំនាស់ទំហំ ៥,៨០ម៉ែត្រ គុណ ៦,៨០ម៉ែត្រ ស្ថិតនៅដីឡូតិ៍លេខ ២៩ ក្រុម ៣៧ ផ្លូវលេខ ៥៥៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញឱ្យនៅសភាពដើមវិញ ប៉ុន្តែតាមការបញ្ជាក់របស់ចុងចម្លើយឈ្មោះ[redacted] ចាន់ណារីដីទំនាស់មានទំហំ៨,៨០ម៉ែត្រ គុណ ៦,៨០ម៉ែត្រ ដែលពួកខ្លួនទាំងបីនាក់បានចាក់ដីប្រើប្រាស់រួមគ្នាពុំមែន



២៥៦

856

Scanned with CamScanner

ជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ឡើយ។

-ដើម្បីការពារផលប្រយោជន៍រួមរបស់ភាគី តុលាការគប្បីទុកដីទំនាស់ទំហំ ៨,៨០ ម៉ែត្រ គុណ ៦,៨០ ម៉ែត្រ ស្ថិតនៅដីឡូត៍លេខ២៩ ក្រុម៣៧ ផ្លូវលេខ៥៥៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឱ្យភាគីចុងចម្លើយទាំងអស់ ប្រើប្រាស់ជាប្រយោជន៍រួមចាប់ពីពេលនេះតទៅ។

-ប្រាក់ពន្ធជាបន្ទុករបស់ដើមចោទ។

## សេចក្ដីសម្រេចបញ្ចប់

១/ ច្រានចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] គឹមថា ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០១១ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

២/ ប្រគល់ដីទំហំ ៨,៨០ ម៉ែត្រ គុណ ៦,៨០ ម៉ែត្រ ស្ថិតនៅដីឡូត៍លេខ ២៩ ក្រុម ៣៧ ផ្លូវលេខ៥៥៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឱ្យចុងចម្លើយឈ្មោះ [redacted] សាវីន ឈ្មោះ [redacted] សីឌី ប្រពន្ធឈ្មោះ [redacted] ចាន់ណារី និងឈ្មោះ [redacted] វណ្ណា ប្រពន្ធឈ្មោះ [redacted] សុភាលី ទុកប្រើប្រាស់ជាប្រយោជន៍រួម ។

៣/ ប្រាក់ពន្ធជាបន្ទុករបស់ដើមចោទ។

៤/សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃ ទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតពីថ្ងៃបានទទួលការបញ្ជូនអនុសារសាលក្រម។

ចៅក្រមជំនុំជម្រះ

ហត្ថលេខា [redacted]

---

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី......ខែកុម្ភៈ ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

បានទទួល

13 02 2012

[redacted]



២៥៧

257